# ព្រះរាជក្រម

នស/រកម/១២៩៩/១៥

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍
## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣និងមាត្រាទាំងឡាយនៃជំពូកទី៨ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចនាយករដ្ឋមន្ត្រី និងរបស់ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## ប្រកាសអោយប្រើ

ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០០ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៩៩ នាសម័យប្រជុំពេញអង្គលើកទី៣ នីតិកាលទី២ និងដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាម លើទំរង់និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី២៨ខែធ្នូ ឆ្នាំ១៩៩៩ នាសម័យប្រជុំពេញអង្គលើកទី២ នីតិកាលទី១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ច្បាប់

# ស្តីពី

# ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង

# ឆ្នាំ ២០០០

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

## ស្តីពីចំណូល ចំណាយនៃថវិកាទូទៅរបស់រដ្ឋ

មាត្រា ១.-

ត្រូវបានអនុញ្ញាតសំរាប់ឆ្នាំ ២០០០ អោយប្រមូលបង់ចូលថវិកាទូទៅរបស់រដ្ឋនូវពន្ធដារ វិភាគទាន អាករ ផលទុន និងចំណូលនានាព្រមទាំងធ្វើអោយសំរេចនូវអំណោយមូលនិធិបរិភាគ និងធនធានបានមកពីការខ្ចី ដូចមានចែងក្នុងតារាង "ក" ដែលភ្ជាប់មកជាមួយច្បាប់នេះ ក្នុងទឹកប្រាក់សរុបចំនួន.................... ២.៣៥៥.០០០ លានរៀល

ដែលត្រូវបានបែងចែកដូចតទៅ :

- ចំណូលជាប្រចាំ.................... ១.៤៨៥.០០០ លានរៀល
- ចំណូលជាមូលធន.................... ៨៧០.០០០ លានរៀល
  - +ចំណូលជាមូលធនក្នុងប្រទេស.................... ២០.០០០ លានរៀល
  - +ចំណូលជាមូលធនក្រៅប្រទេស.................... ៨៥០.០០០ លានរៀល

មាត្រា ២.-

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានសំរាប់ចំណាយក្នុងថវិកាទូទៅរបស់រដ្ឋ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ត្រូវបានកំណត់ស្មើនឹង.................... ២.៣៥៩.០០០ លានរៀល

ដែលត្រូវបានបែងចែកដូចតទៅ :

- ចំណាយជាប្រចាំ.................... ១.៣១៩.០០០ លានរៀល
- ចំណាយជាមូលធន.................... ១.០៤០.០០០ លានរៀល
  - +ចំណាយវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេស.................... ៣២០.០០០ លានរៀល
    - • ដោយមូលនិធិថវិកា.................... ១៧០.០០០ លានរៀល
    - • ដោយមូលនិធិក្រៅប្រទេសដែលអ្នកផ្តល់អំណោយបានយល់ព្រមជាមុន.................... ១៥០.០០០ លានរៀល
  - +ចំណាយវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ដែលអនុវត្តក្រៅរតនាគារជាតិ.................... ៧០០.០០០ លានរៀល
  - +ចំណាយរំលស់បំណុល.................... ២០.០០០ លានរៀល

មាត្រា ៣.-

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានសំរាប់ចំណាយជាប្រចាំរបស់រដ្ឋ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ត្រូវបានកំណត់ស្មើនឹង........................................ ១.៣១៥.០០០ លានរៀល

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ និងទៅតាមប្រភេទនៃជំពូកដូចមានចែងក្នុងតារាង "ខ" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

មាត្រា ៤.-

ចំនួនទឹកប្រាក់នៃឥណទានកម្មវិធីរបស់រដ្ឋសំរាប់ការគ្រប់គ្រងពីឆ្នាំ ២០០០ ដល់ ២០០២ ត្រូវបានកំណត់ស្មើនឹង........................................ ៤.១៣០.០៧៩ លានរៀល

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ តាមគំរោងនិងតាមឆ្នាំដូចមានចែងក្នុងតារាង "គ" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

មាត្រា ៥.-

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានភ្ជាប់សន្យានិងឥណទានទូទាត់សំរាប់ចំណាយជាមូលធននៃថវិការដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ត្រូវបានកំណត់ដូចតទៅ :

-ឥណទានភ្ជាប់សន្យា........................................ ១.៣៤០.០០០ លានរៀល

-ឥណទានទូទាត់........................................ ១.០៤០.០០០ លានរៀល

ឥណទាននេះ ត្រូវបានបែងចែកដូចតទៅ :

ក. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស :

-ឥណទានភ្ជាប់សន្យា........................................ ៣២០.០០០ លានរៀល

-ឥណទានទូទាត់........................................ ៣២០.០០០ លានរៀល

ខ. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ :

-ឥណទានភ្ជាប់សន្យា........................................ ១.០០០.០០០ លានរៀល

-ឥណទានទូទាត់........................................ ៧០០.០០០ លានរៀល

គ. ការវិលសំប៉ណុលសាធារណៈ :

-ឥណទានភ្ជាប់សន្យា........................................ ២០.០០០ លានរៀល

-ឥណទានទូទាត់........................................ ២០.០០០ លានរៀល

ឥណទាននេះ ត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ និងតាមជំពូកថវិកាដូចមានចែងក្នុងតារាង "ឃ" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

# ជំពូកទី ២

## បទប្បញ្ញត្តិ

## ស្តីពីលំនឹងចំណូលតុល្យភាពនៃថវិកាទូទៅរបស់រដ្ឋ

មាត្រា ៦.-

តុល្យភាពនៃថវិកាទូទៅរបស់រដ្ឋ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលបានរៀបចំឡើងដោយតារាង "ក" ស្តីពីចំណូលថវិកាទូទៅរបស់រដ្ឋនិងតារាង "ខ" ស្តីពីចំណាយថវិកាទូទៅរបស់រដ្ឋត្រូវបានបង្ហាញនៅក្នុងតារាងនៃកិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋដូចតទៅ :

ឯកតា: លានរៀល

| កិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ | ចំនួនទឹកប្រាក់ | ចំនួនលើស (+) ឱនភាព (-) |
|---|---|---|
| I. ចំណូលក្នុងប្រទេស | ១.៥០៩.០០០ | |
| ១.ចំណូលជាប្រចាំ | ១.៤៨៩.០០០ | |
| ២.ចំណូលជាមូលធនក្នុងប្រទេស (ឯកជនភាវូបនីយកម្ម) | ២០.០០០ | |
| II. សរុបចំណាយថវិកា[1] | ២.៣៣៩.០០០ | |
| ១. ចំណាយជាប្រចាំ | ១.៣១៩.០០០ | |
| ២. ចំណាយជាមូលធន[1] | ១.០២០.០០០ | |
| - វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | ៣២០.០០០ | |
| + ដោយមូលនិធិថវិកា | ១៧០.០០០ | |
| • គំរោងវិនិយោគ (សាងសង់ - ទព្វសម្ភារៈ) | ៧០.០០០ | |
| • បដិភាគរួមចំណែកជាមួយវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ | ១០០.០០០ | |
| + ដោយមូលនិធិក្រៅប្រទេសដែលមានការយល់ព្រមជាមុនពីអ្នកផ្តល់ជំនួយ | ១៥០.០០០ | |
| - វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ | ៧០០.០០០ | |
| អតិរេកនៃថវិកាជាប្រចាំ | | +១៧០.០០០ |
| ឱនភាពសរុបនៃថវិកាទូទៅ | | -៨៣០.០០០ |
| III. ហិរញ្ញប្បទាននៃឱនភាព | | +៨៣០.០០០ |
| ១. ហិរញ្ញប្បទានក្រៅប្រទេស | | +៨៥០.០០០ |
| - ជំនួយទ្រទ្រង់ថវិកាដែលមានការយល់ព្រមជាមុនពីអ្នកផ្តល់ជំនួយ | | +១៥០.០០០ |
| - ជំនួយគំរោងការ | | +៧០០.០០០ |
| ២. ការរំលស់បំណុល | | -២០.០០០ |
| ៣. ហិរញ្ញប្បទានធនាគារ | | ០ |

[1] មិនគិតការរំលស់បំណុល (២០.០០០ លានរៀល) ដែលមានកំណត់នៅក្នុងចំណុច III "ហិរញ្ញប្បទាននៃឱនភាព" ។

# ជំពូកទី ៣

## បទប្បញ្ញត្តិ
## ស្តីពីចំណូលថវិកា

មាត្រា ៧.–

ក្នុងករណីដែលកិច្ចសន្យាពាក់ព័ន្ធទៅនឹងការលក់ ការជួលចលនវត្ថុ ឬអចលនវត្ថុ ដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ ឬក្នុងករណីដែលកិច្ចសន្យាពាក់ព័ន្ធទៅនឹងសេវាបង់ថ្លៃរបស់រដ្ឋពុំមានចែងអំពីការពិន័យទេនោះ មុនឈានដល់ការរំលាយចោលកិច្ចសន្យាដូចមានចែងក្នុងមាត្រា ១១ នៃច្បាប់នេះ ត្រូវអនុវត្តការពិន័យពីរ (២) ភាគរយក្នុងមួយខែ លើចំនួនទឹកប្រាក់ដែលមិនទាន់បានទូទាត់ជូនរដ្ឋ ចាប់ពីហុកសិប (៦០) ថ្ងៃក្រោយការកំណត់តទៅ ។

បទប្បញ្ញត្តិនេះមិនអនុវត្តចំពោះកិច្ចសន្យាទាំងឡាយណាដែលមានចែងអំពីការពិន័យរួចហើយនោះទេ ។

# ជំពូកទី ៤

## បទប្បញ្ញត្តិ
## ស្តីពីការកែប្រែមាត្រា ៣ មាត្រា ១៧ និង មាត្រា ៤៨
## នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ

មាត្រា ៨.–

មាត្រា ៣ មាត្រា ១៧ និងមាត្រា ៤៨ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១នស៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ត្រូវបានកែប្រែដោយបទប្បញ្ញត្តិដូចតទៅ :

មាត្រា៣ (ថ្មី)

គណនីថវិការួមមានថវិកាទូទៅរបស់រដ្ឋ *ថវិកាឧបសម្ព័ន្ធ* *ថវិកានៃគ្រឹះស្ថានសាធារណៈរដ្ឋបាល* និងគណនីពិសេសនៃរតនាគារ ។ គណនីថវិកាផ្សេងៗទៀត អាចបង្កើតបានក្នុងច្បាប់ហិរញ្ញវត្ថុ ។

ថវិកាឧបសម្ព័ន្ធត្រូវអនុវត្តចំពោះអង្គភាពរដ្ឋដែលមានលក្ខណៈឧស្សាហកម្មនិងពាណិជ្ជកម្ម តែពុំមែនជានីតិបុគ្គលទេ ។ ថវិកាឧបសម្ព័ន្ធត្រូវបានបង្កើត ឬលុបចោលដោយច្បាប់ហិរញ្ញវត្ថុ ។ កិច្ចប្រតិបត្តិការនៃថវិកាឧបសម្ព័ន្ធ ត្រូវប្រព្រឹត្តទៅក្នុងល័ក្ខខ័ណ្ឌនិងតាមវិធានដូចគ្នានៃកិច្ចប្រតិបត្តិការរបស់រដ្ឋដែរ ។

គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវមានថវិកាស្វយ័ត ។ ប្រភពធនធានជាប្រចាំរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលរួមមានចំណូលផ្ទាល់និងជាយថាហេតុ មានការឧបត្ថម្ភធនព្យុភាពដោយថវិកាទូទៅរបស់រដ្ឋ ។ រីឯចំណាយជាប្រចាំរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវគោរពតាមវិធាននៃចំណាត់ថ្នាក់និងការគ្រប់គ្រងដូចចំណាយជាប្រចាំរបស់រដ្ឋដែរ ។

ការរៀបចំនិងការប្រព្រឹត្តិទៅនៃថវិកាឧបសម្ព័ន្ធដែលជាអង្គភាពរដ្ឋ ឬជាគ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា១៧ (ថ្មី)

ឥណទានថវិកាដែលបានអនុញ្ញាតដោយច្បាប់ហិរញ្ញវត្ថុ ត្រូវបានបែងចែកនៅផ្ទៃក្នុងប្រភេទនីមួយៗ ជាជំពូក, ប្រការ, កថាខ័ណ្ឌ និងអនុខ័ណ្ឌទៅតាមលក្ខណៈឬគោលដៅនៃឥណទានថវិកា ។

ឥណទានទាំងនេះ ក៏អាចធ្វើជាកម្មវត្ថុនៃការប្រមូលផ្តុំតាមផ្នែកដែរ ។

ចំណាត់ថ្នាក់ចំណាយ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ចំណាយជាប្រចាំនៃប្រភេទ២: -*ការប្រាក់នៃការខ្ចី* -និងប្រភេទ៤: -*ចំណាយផ្សេងៗ និងចំណាយមិនបានគ្រោងទុក* ព្រមទាំងចំណាយជាមូលធននៃការសងបំណុលមិនត្រូវបានបែងចែកទៅអោយក្រសួងណា ឬស្ថាប័នសាធារណៈប្រហាក់ប្រហែលណាមួយឡើយ ។

ប្រភេទ៤ នៃចំណាយជាប្រចាំ គឺមួយផ្នែកសំរាប់ចំណាយផ្សេងៗ ចំណាយសំណង ឬចំណាយបង្វិលសងវិញ ព្រមទាំងឥណទានត្រៀមបំរុង និងមួយផ្នែកទៀតសំរាប់ចំណាយមិនបានគ្រោងទុក ។

ឥណទានត្រៀមបំរុងត្រូវបានអនុញ្ញាតសំរាប់ការចំណាយទាំងឡាយណា ដែលការបែងចែកមិនអាចត្រូវបានកំណត់ជាក់លាក់នៅពេលដែលឥណទាននោះត្រូវបានអនុម័ត ។ ការបែងចែកឥណទានត្រៀមបំរុងទាំងនេះ តាមក្រសួងនីមួយៗនិងស្ថាប័នសាធារណៈប្រហាក់ប្រហែលនីមួយៗ ត្រូវធ្វើឡើងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

*រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុគឺជាអាណាប័កចំណាយលើការប្រាក់នៃការខ្ចី ចំណាយផ្សេងៗ ចំណាយសំណង និងចំណាយបង្វិលសងវិញព្រមទាំងចំណាយសងបំណុល ។*

មាត្រា៤៨ (ថ្មី)

ការអនុវត្តនីតិកិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋនិងគណនីពិសេសរបស់រតនាគារ ជាភារកិច្ចរបស់អាណាប័កនិងគណនេយ្យករសាធារណៈ ។ អាណាប័កនិងគណនេយ្យករសាធារណៈ មានមុខងារវិសមតភាពពីគ្នា ។

រដ្ឋមន្ត្រីនិងប្រធានស្ថាប័នសាធារណៈប្រហាក់ប្រហែល ជាអាណាប័កដើមខ្សែនៃថវិការដ្ឋចំពោះផ្នែកចំណូលដែលបានមកពីផ្នែករបស់ខ្លួន និងចំពោះផ្នែកចំណាយនៅរដ្ឋបាលកណ្តាល និងនៅអង្គភាព

ខាងក្រៅដែលស្ថិតក្រោមនិវាទនៅតាមខេត្ត ក្រុង ។ រដ្ឋមន្ត្រីនិងប្រធានស្ថាប័នសាធារណៈប្រហាក់ប្រហែលជាអ្នកបញ្ជាចំណូលចំណាយថវិកាតាមផ្នែករៀងៗខ្លួន ។

រដ្ឋមន្ត្រីនិងប្រធានស្ថាប័នសាធារណៈប្រហាក់ប្រហែលជាអាណាប័កដើមខ្សែនៃថវិការបស់ខ្លួន ប្រគល់សិទ្ធិជូនអភិបាលខេត្ត ក្រុង ជាអាណាប័កផ្ទេរសិទ្ធិសំរាប់កិច្ចប្រតិបត្តិការហិរញ្ញវត្ថុថវិការដ្ឋក្នុងមណ្ឌលដែនដីរបស់ខ្លួន ។

*រដ្ឋមន្ត្រីនិងប្រធានស្ថាប័នសាធារណៈប្រហាក់ប្រហែលដែលជាអាណាប័កដើមខ្សែនៃថវិការបស់ខ្លួនអាចប្រគល់សិទ្ធិជូនប្រធានមន្ទីរជំនាញខេត្ត ក្រុង ជាអាណាប័កផ្ទេរសិទ្ធិសំរាប់កិច្ចប្រតិបត្តិការហិរញ្ញវត្ថុ ថវិការដ្ឋនៅក្នុងមណ្ឌលដែនដីរបស់ខ្លួន បន្ទាប់ពីមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។*

បទបញ្ជានៃគណនេយ្យសាធារណៈ ជ្រើសតាំងប្រភេទមន្ត្រីរាជការដែលអាណាប័កដើមខ្សែអាចផ្ទេរសិទ្ធិ ឬជំនួសខ្លួនក្នុងករណីដែលអាណាប័កដើមខ្សែអវត្តមាន ឬមានធុរៈ ។ ការផ្ទេរសិទ្ធិ ឬការចុះហត្ថលេខា ត្រូវធ្វើឡើងដោយប្រកាសបន្ទាប់ពីមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ៥

## បទប្បញ្ញត្តិ

## ស្តីពីការទទួលខុសត្រូវនៃអ្នកគ្រប់គ្រងប្រាក់កាសសាធារណៈ

មាត្រា ៩.-

ហាមឃាត់ដាច់ខាតមិនអោយប្រធានស្ថាប័នរដ្ឋបាលនិងអាណាប័កដើមខ្សែ ព្រមទាំងអាណាប័កផ្ទេរសិទ្ធិ ចាត់វិធានការទាំងឡាយណាដែលនាំអោយកើនចំណាយលើឥណទានថវិកាទូទៅរបស់រដ្ឋដែលពុំមានចែងក្នុងច្បាប់ហិរញ្ញវត្ថុ ឬច្បាប់ អនុក្រឹត្យនិងបទបញ្ជាដែលមានពីមុនកិច្ចសន្យាចំណាយ ។

មាត្រា ១០.-

ដោយអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា ១៨ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១នស៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ត្រូវបានចាត់ទុកជាកំហុសនៃការគ្រប់គ្រងដែលបានប្រព្រឹត្តចំពោះរដ្ឋដូចជា :

-រាល់អំពើដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិដូចមានចែងក្នុងច្បាប់នេះ ។

-រាល់អំពើដែលបានចុះកិច្ចសន្យាចំណាយលើសឥណទានថវិកាដែលបានអនុម័តដោយរដ្ឋសភា លើកលែងតែឥណទានដែលបានគ្រោងទុកសំរាប់បើកបៀវត្ស និងប្រាក់វិភាជន៍សង្គម សោវ

បំណុលនិងសងប្រាក់ខ្ចីដែលបានយល់ព្រមដោយរដ្ឋសភាព្រមទាំងការបង់វិភាគទានចំពោះអង្គការអន្តរ-ជាតិនានា ។

-រាល់អំពើដែលជាកម្មវត្ថុសំរាប់បង្កើនទឹកប្រាក់ឥណទានថវិកាដែលបានទទួលការអនុញ្ញាតពីរដ្ឋសភាដោយធនបានពិសេស ក្រៅពីករណីដែលបានកំណត់ដោយច្បាប់ និងបទបញ្ជាជាធរមាន និងដោយអនុសញ្ញាអន្តរជាតិដែលរដ្ឋសភាបានអនុម័តយល់ព្រម ។

-រាល់កំហុសធ្ងន់ធ្ងរដែលនាំអោយមានការខាតបង់ប្រាក់កាសដែលហិរញ្ញវត្ថុសាធារណៈទទួលបន្ទុក ។

-រាល់សកម្មភាពគ្រប់គ្រងដែលប្រព្រឹត្តល្មើសនឹងច្បាប់ អនុក្រឹត្យ និងបទបញ្ជាដែលអនុវត្តចំពោះចំណូលនិងចំណាយរបស់រដ្ឋ ។

## មាត្រា ១១.-

ដោយអនុលោមទៅតាមមាត្រា ៩ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១នស៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ "កិច្ចប្រតិបត្តិការជាលក្ខណៈពាណិជ្ជកម្មដែលទទួលធ្វើដោយអង្គភាពរបស់រដ្ឋដោយផ្ទាល់ ត្រូវបានដឹកនាំតាមទម្លាប់ប្រើប្រាស់ជាធរមានក្នុងវិស័យឧស្សាហកម្មនិងពាណិជ្ជកម្មក្រោមការត្រួតពិនិត្យរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ"។

ជាពិសេសកិច្ចសន្យាស្តីពីសម្បទានលើធនធាននៃទ្រព្យសម្បត្តិរដ្ឋ ឬការលក់ផលិតផលនៃអាជីវកម្ម ត្រូវបានសំរេចដោយផ្អែកទៅតាមល័ក្ខខ័ណ្ឌនិងបែបបទជាធរមាននៅលើទីផ្សារអន្តរជាតិនិងស្របទៅតាមតម្លៃជាក់ស្តែងនៃទីផ្សារ ។

ត្រូវរំលាយចោលនូវរាល់កិច្ចសន្យាដែលទាក់ទងទៅនឹងការលក់ ឬការជួលចលនវត្ថុ ឬអចលនវត្ថុដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងរាល់ការចាត់ចែងប្រើប្រាស់ទ្រព្យសម្បត្តិទាំងឡាយនោះ ក្នុងករណីដែលប្រធានស្ថាប័នបានធ្វើលិខិតតវ៉ាហើយ តែអ្នកទិញ អ្នកជួល ឬអ្នកទទួលផលប្រយោជន៍នៅតែមិនគោរពតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងកិច្ចសន្យា ដូចជាការទូទាត់ថ្លៃលក់ ឬការបង់ថ្លៃឈ្នួលមិនបានទាន់ពេលវេលា ។

ត្រូវរំលាយចោលនូវកិច្ចសន្យាដូចគ្នានេះដែរ ចំពោះសេវាបង់ថ្លៃរបស់រដ្ឋដែលបានចុះកិច្ចសន្យារវាងសេវាសាធារណៈនិងឯកជនឬអង្គការតតិយ ក្នុងករណីដែលកិច្ចសន្យាទាំងឡាយនោះធ្វើអោយប៉ះពាល់ដល់ចំណូលរបស់រដ្ឋ ឬអ្នកទទួលផលប្រយោជន៍មិនបានគោរពតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងកិច្ចសន្យា ។

មាត្រា ១២.-

ត្រូវបង់ចូលថវិកាទូទៅរបស់រដ្ឋ នូវចំណូលទាំងអស់ដែលបានមកពីកិច្ចប្រតិបត្តិការដូចមានបញ្ជាក់នៅក្នុងមាត្រា ១១ នៃច្បាប់នេះ ដោយគ្មានកាត់កងនូវចំណូលទាំងនោះសំរាប់ទូទាត់សោហ៊ុយចំណាយនៃកិច្ចប្រតិបត្តិការនោះឡើយ ។

មាត្រា ១៣.-

ប្រធានស្ថាប័ន អាណាប័កដើមខ្សែ និងអាណាប័កតាមការប្រទានសិទ្ធិ ព្រមទាំងមន្ត្រីរាជការនិងភ្នាក់ងាររដ្ឋ ត្រូវទទួលខុសត្រូវដោយផ្ទាល់លើការប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិដែលមានចែងក្នុងជំពូកនេះ ។

ប្រធានស្ថាប័នត្រូវធ្វើរបាយការណ៍ប្រចាំត្រីមាសស្តីពីការអនុវត្តន៍ចំណូល ចំណាយថវិការបស់ខ្លួន និងធ្វើរបាយការណ៍ស្តីពីសភាពការណ៍នៃការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋដែលបានប្រគល់អោយខ្លួនកាន់កាប់ជូនគណៈរដ្ឋមន្ត្រីពិនិត្យសំរេចតាមរយៈរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយបង្ហាញនូវលទ្ធផលដែលសំរេចបាន និងការខ្វះខាតដែលបានកត់សំគាល់ឃើញដោយប្រៀបធៀបទៅនឹងគំរោង និងគោលដៅព្រមទាំងលើកវិធានការកែលំអនូវការខ្វះខាតទាំងនោះ ។

## ជំពូកទី ៦

## បទប្បញ្ញត្តិ

## ស្តីពីការខ្ចីនិងការធានារបស់រដ្ឋ

មាត្រា ១៤.-

ចំនួនទឹកប្រាក់ជាអតិបរមាដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវបានអនុញ្ញាតអោយខ្ចីមានកំរិតរហូតដល់ ២០០.០០០.០០០ S.D.R (ពីររយលាន អេសដេអ៊ែ) សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ។

នៅក្នុងល័ក្ខខ័ណ្ឌនេះ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាអ្នកមានសិទ្ធិស្របច្បាប់តែមួយគត់ តាមការប្រទានសិទ្ធិជាលាយលក្ខអក្សររបស់នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលក្នុងការចុះហត្ថលេខាលើការខ្ចីជាគុណប្រយោជន៍នៃថវិកាទូទៅរបស់រដ្ឋ ឬលើការធានារបស់រដ្ឋ ។

ការខ្ចីដែលត្រូវចុះកិច្ចសន្យាក្នុងកំរិតខាងលើ ត្រូវមានលក្ខណៈជាការខ្ចីសម្បទានដែលត្រូវសងវិញជាមួយការប្រាក់អនុគ្រោះ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានការឯកភាពពីធនាគារជាតិនៃកម្ពុជាត្រូវបានទទួលការអនុញ្ញាតអោយលក់ប័ណ្ណរតនាគារក្នុងកំរិតទឹកប្រាក់ចំនួន ៥០.០០០.០០០.០០០រ (ហាសិបពាន់លានរៀល) ដើម្បីបំពាក់ទូរនិនភាពថវិកា ឬសំរាប់ដោះស្រាយតំរូវការជាបន្ទាន់ខាងសាច់ប្រាក់ ។ លក្ខខ័ណ្ឌនៃការលក់ប័ណ្ណរតនាគារនេះ ត្រូវកំណត់ដោយលិខិតបទដ្ឋានស្របច្បាប់ ។

រាល់ការខ្ចីនិងការធានារបស់រដ្ឋតាមលក្ខខ័ណ្ឌពាណិជ្ជកម្មសំរាប់ការគ្រប់គ្រងថវិកាឆ្នាំ ២០០០ ត្រូវអនុម័តពីរដ្ឋសភានិងព្រឹទ្ធសភាតាមតំរោងនីមួយៗ ។

មាត្រា ១៥.-

មិនអនុញ្ញាតអោយក្រសួង ឬស្ថាប័នសាធារណៈចំណុះរដ្ឋណាមួយមានសិទ្ធិចុះហត្ថលេខាក្រោមរូបភាពបោះផ្សាយមូលប័ត្ររយៈពេលវែង មធ្យម ខ្លី ឬឥណទានអ្នកផ្គត់ផ្គង់ ឬចុះកិច្ចសន្យាក្រោមរូបភាពទទួលបន្ទុកខ្ចី ឬការធានាកិច្ចសន្យាដែលបានចុះហត្ថលេខាដោយស្ថាប័នសាធារណៈ ឬឯកជន ឬចុះកិច្ចសន្យាក្រោមរូបភាពកិច្ចសន្យាផ្សេងៗទៀត ដែលត្រូវសងបំណុលតាមកាលកំណត់ ឬតាមឆ្នាំដែលស្ថិតនៅក្រៅការអនុញ្ញាតនៃច្បាប់ហិរញ្ញវត្ថុ និងលក្ខខ័ណ្ឌទាំងឡាយដែលច្បាប់នេះបានកំណត់នោះទេ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តន៍បទប្បញ្ញត្តិនៃជំពូកនេះជូនរដ្ឋសភានិងព្រឹទ្ធសភារៀងរាល់ ៦ខែម្តង ។

# ជំពូកទី ៧

## បទប្បញ្ញត្តិ

## ស្តីពីថវិការបស់ខេត្ត ក្រុង សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០

មាត្រា ១៦.-

ដោយអនុលោមទៅតាមបទប្បញ្ញត្តិនៃមាត្រា ១៨ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង ដែលបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ កញ្ចប់ថវិការួមនៃថវិការបស់ខេត្ត ក្រុង សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ត្រូវបានកំណត់ជាចំណូលនិងចំណាយចំនួន ......................................៤៤.០០០ លានរៀល

ដែលបានមកពីចំណូលសារពើពន្ធនិងពុំមែនសារពើពន្ធផ្ទាល់របស់ខេត្ត ក្រុងចំនួន..២៤.០០០ លានរៀល

និងទទួលការឧបត្ថម្ភពីថវិការដ្ឋចំនួន......................................................២០.០០០ លានរៀល

ការបែងចែកកញ្ចប់ថវិការួមនេះទៅតាមខេត្ត ក្រុងនីមួយៗក៏ដូចជាបែងចែកឥណទានទៅផ្នែកក្នុង ថវិកានេះ ជាជំពូក, ប្រការ, កថាខ័ណ្ឌនិងអនុកថាខ័ណ្ឌ ត្រូវធ្វើឡើងតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីបានទទួលយោបល់ឯកភាពពីក្រសួងមហាផ្ទៃ ។

## ជំពូកទី៨

## អវសានប្បញ្ញត្តិ

មាត្រា ១៧ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១៨ .-

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

រាជធានីភ្នំពេញ ,ថ្ងៃទី២៥ខែ ធ្នូ ឆ្នាំ១៩៩៩

ព្រះហស្តលេខា

នរោត្តម សីហនុ

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជំរាបជូន សម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា

គាត ឈន់

លេខ : ២ ៤៣ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ១៩៩៩

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible]

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
ទំព័រ ១.៥

# ការគ្រប់គ្រងឆ្នាំ ២០០០

## តារាង "ក"

## ចំណូលថវិកាទូទៅរបស់រដ្ឋ

ការប្រមាណចំណូលតាមប្រភេទ ជំពូក ប្រការ កថាខណ្ឌ និង អនុខណ្ឌ

ឯកតា: លានរៀល

| ជំពូក | ប្រការ | កថាខណ្ឌ | អនុខណ្ឌ | ការរាយមុខចំណូល | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ១៩៩៩ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០០០ | លំអៀង ខ្វះ | លំអៀង លើស |
|---|---|---|---|---|---|---|---|---|
| | | | | **សរុបរួមគិតប្រតិបត្តិការថវិកា** | 1 495 000.0 | 2 355 000.0 | | +860 000 |
| | | | | **ក្នុងនោះចំណូលក្នុងស្រុក** | 1 245 000.0 | 1 505 000.0 | | +260 000 |
| | | | | **សរុបចំណូលជាប្រចាំ** | 1 220 000.0 | 1 485 000.0 | | +265 000 |
| | | | | **ប្រភេទទី១: ពន្ធ និង អាករ** | 853 280.0 | 1 065 000.0 | | +211 720 |
| 10 | | | | ជំពូក១០: ពន្ធលើផលទុនប្រាក់ចំណេញ និង កំរៃទុន | 81 000.0 | 103 600.0 | | +22 600 |
| | 01 | | | ពន្ធលើប្រាក់បៀវត្ស | 15 000.0 | 15 000.0 | | |
| | 02 | | | ពន្ធលើប្រាក់ចំណេញ | 60 000.0 | 81 600.0 | | +21 600 |
| | | 01 | | សហគ្រាសសាធារណៈ | 8 000.0 | 8 000.0 | | |
| | | | 01 | សហគ្រាសមជ្ឈិម | 8 000.0 | 8 000.0 | | |
| | | | 02 | សហគ្រាសខេត្តនានា | | | | |
| | | 02 | | សហគ្រាសឯកជន | 52 000.0 | 73 600.0 | | +21 600 |
| | 05 | | | ពន្ធលើផលទុននៃដីធ្លី . ផ្ទះសំបែង | 6 000.0 | 7 000.0 | | +1 000 |
| | 08 | | | ពន្ធលើដីធ្លីមិនបានប្រើប្រាស់ (២) | | | | |
| 11 | | | | ជំពូក១១: ពន្ធលើបេតិកភ័ណ្ឌ | | | | |
| | 01 | | | ពន្ធប្រថាប់ត្រា (២) | | | | |
| | | 01 | | ពន្ធផ្ទេរមតិករវាងអ្នកនៅរស់ | | | | |
| | | 02 | | ពន្ធផ្ទេរសិទ្ធិពីអ្នកស្លាប់ | | | | |
| 12 | | | | ជំពូក១២: ពន្ធផ្ទៃក្នុងលើទ្រព្យសម្បត្តិនិងសេវា | 326 680.0 | 465 000.0 | | +138 320 |
| | 01 | | | អាករលើផលរបរ: របបផ្ទៃក្នុង | 16 000.0 | 12 000.0 | -4 000 | |
| | | 01 | | សហគ្រាសសាធារណៈ | | | | |
| | | | 01 | សហគ្រាសមជ្ឈិម | | | | |
| | | | 02 | សហគ្រាសខេត្តនានា | | | | |
| | | 02 | | សហគ្រាសឯកជន | 16 000.0 | 12 000.0 | -4 000 | |
| | 02 | | | អាករលើតំលៃបន្ថែម : របបផ្ទៃក្នុង | 63 000.0 | 73 000.0 | | +10 000 |
| | | 01 | | សហគ្រាសសាធារណៈ | 3 000.0 | 3 000.0 | | |
| | | 02 | | សហគ្រាសឯកជន | 60 000.0 | 70 000.0 | | +10 000 |
| | | | 01 | សហគ្រាសប្រេងឥន្ធនៈ | | | | |
| | | | 02 | សហគ្រាសផ្សេងៗ | | | | |
| | 03 | | | ពន្ធប៉ាតង់ (២) | | | | |
| | 04 | | | អាករពិសេសលើទំនិញមួយចំនួន និងសេវាកម្ម | 80 000.0 | 94 000.0 | | +14 000 |
| | | 01 | | របបផ្ទៃក្នុង | 20 000.0 | 22 000.0 | | +2 000 |
| | | 02 | | របបនៃការនាំចូល | 60 000.0 | 72 000.0 | | +12 000 |
| | | | 01 | សហគ្រាសប្រេងឥន្ធនៈ | | | | |
| | | | 02 | សហគ្រាសផ្សេងៗ | | | | |

# ការគ្រប់គ្រងឆ្នាំ ២០០០

## តារាង "ក"

## ចំណូលថវិកាចរន្តរបស់រដ្ឋ

ការប្រមាណចំណូលតាមប្រភេទ ជំពូក ប្រការ កថាខណ្ឌ និង អនុកថាខណ្ឌ

ឯកតា: លានរៀល

| ជំពូក | ប្រការ | កថាខណ្ឌ | អនុកថាខណ្ឌ | ការរាយមុខចំណូល | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ១៩៩៩ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០០០ | លំអៀង ខ្វះ | លំអៀង លើស |
|---|---|---|---|---|---|---|---|---|
| | 05 | | | ពន្ធសត្វឃាត (២) | | | | |
| | 06 | | | ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានយន្តគ្រប់ប្រភេទ (២) | | | | |
| | 08 | | | អាករលើតំលៃបន្ថែម : របបនាំចូល | 167 680.0 | 286 000.0 | | +118 320 |
| | | 01 | | សហគ្រាសប្រេងឥន្ធនៈ | 55 680.0 | 56 000.0 | | +320 |
| | | 02 | | សហគ្រាសផ្សេងទៀត | 112 000.0 | 230 000.0 | | +118 000 |
| 13 | | | | ជំពូក១៣: ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 440 700.0 | 492 000.0 | | +51 300 |
| | 01 | | | ពន្ធ និង អាករគយពីការនាំចូល | 433 000.0 | 480 500.0 | | +47 500 |
| | | 01 | | ពន្ធគយពីការនាំចូល | 235 000.0 | 290 000.0 | | +55 000 |
| | | 02 | | កំរៃយកមុនលើផលិតផលប្រេងកាត | 2 000.0 | 2 500.0 | | +500 |
| | | 03 | | កំរៃយកមុនលើការងារគយក្នុងការនាំចូល | 6 000.0 | 7 000.0 | | +1 000 |
| | | 04 | | ពន្ធគយលើផលិតផលប្រេងកាត | 155 000.0 | 146 000.0 | -9 000 | |
| | | 05 | | អាករបន្ថែមនៃពន្ធគយលើផលិតផលប្រេងកាតសំរាប់ថែទាំផ្លូវថ្នល់ | 35 000.0 | 35 000.0 | | |
| | | 10 | | ពន្ធ និង អាករគយផ្សេងៗទៀតពីការនាំចូល | | | | |
| | 02 | | | អាករពីការនាំចេញ | 4 700.0 | 8 500.0 | | +3 800 |
| | | 01 | | អាករគយពីការនាំចេញ | 4 700.0 | 8 500.0 | | +3 800 |
| | | | 01 | អាករលើការនាំឈើចេញ | 2 500.0 | 5 000.0 | | +2 500 |
| | | | 02 | អាករលើការនាំកៅស៊ូចេញ | 1 000.0 | 2 000.0 | | +1 000 |
| | | | 03 | អាករលើការនាំផលិតផលផ្សេងៗចេញ | 1 200.0 | 1 500.0 | | +300 |
| | | 02 | | កំរៃយកមុនលើការងារគយក្នុងការនាំចេញ | | | | |
| | | 10 | | ពន្ធ និង អាករគយផ្សេងៗទៀតពីការនាំចេញ | | | | |
| | 03 | | | ការផាកពិន័យរបស់គយ | 3 000.0 | 3 000.0 | | |
| 14 | | | | ជំពូក១៤: ចំណូលសារពើពន្ធផ្សេងៗទៀត | 4 900.0 | 4 400.0 | -500 | |
| | 01 | | | ពន្ធតែមប្រ៍ | 1 900.0 | 1 900.0 | | |
| | 04 | | | ការផាកពិន័យ និង ទោសបញ្ញត្តិសារពើពន្ធ | 3 000.0 | 2 500.0 | -500 | |
| | 05 | | | អាករលើយានយន្តនាំចូលដោយផ្ទុយនឹងច្បាប់ | | | | |
| | 10 | | | ចំណូលសារពើពន្ធផ្សេងៗទៀតតាមមុខពន្ធនានា | | | | |
| | | | | **ប្រភេទទី២: ចំណូលមិនមែនសារពើពន្ធ** | 366 720.0 | 420 000.0 | | +53 250 |
| 20 | | | | ជំពូក២០: ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 169 695.0 | 171 790.0 | | +2 095 |
| | 01 | | | ផលនេសាទ | 15 000.0 | 12 680.0 | -2 320 | |
| | 02 | | | ផលព្រៃឈើ | 73 000.0 | 51 500.0 | -21 500 | |
| | 03 | | | ផលទុនបានមកពីសហគ្រាសសាធារណៈ | 47 580.0 | 65 575.8 | | +17 996 |
| | | 01 | | ការជួលភោគចក្រសហគ្រាស | 8 210.0 | 16 480.0 | | +8 270 |
| | | | 01 | សហគ្រាសមធ្យម | 8 210.0 | 16 295.0 | | +8 085 |
| | | | 02 | សហគ្រាសខេត្តនានា | | 185.0 | | +185 |

# ការគ្រប់គ្រងឆ្នាំ ២០០០

## តារាង "ក"

## ចំណូលថវិកាចរន្តរបស់រដ្ឋ

ការប្រមាណចំណូលតាមប្រភេទ ជំពូក ប្រការ កថាខណ្ឌ និង អនុកថាខណ្ឌ

ឯកតា: លានរៀល

| ជំពូក | ប្រការ | កថាខណ្ឌ | អនុកថាខណ្ឌ | ការរាយមុខចំណូល | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ១៩៩៩ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០០០ | លំអៀង ខ្វះ | លំអៀង លើស |
|---|---|---|---|---|---|---|---|---|
| | | 02 | | ការបង់ប្រាក់សេសសល់ឡើងវិញ | 2 190.0 | 1 860.0 | -330 | |
| | | | 01 | សហគ្រាសមធ្យម | 2 190.0 | 1 860.0 | -330 | |
| | | | 02 | សហគ្រាសខេត្តនានា | | | | |
| | | 03 | | ចំនួនលើសនៃខ្ទង់ចល័ត | | | | |
| | | 04 | | សេវាកម្មនៃការខ្ចីឯការរបស់សហគ្រាសសាធារណៈ | | | | |
| | | 05 | | ប្រាក់ចំណេញរបស់សហគ្រាសសាធារណៈ | | | | |
| | | 06 | | ផលខ្ទង់របស់អាកាសចរណ៍ស៊ីវិល | 27 100.0 | 42 560.0 | | +15 45[illegible] |
| | | 07 | | ផលខ្ទង់នៃសកម្មភាពភាពយន្ត | | | | |
| | | 08 | | ផលខ្ទង់នៃសកម្មភាពទេសចរណ៍ | 9 800.0 | 4 200.0 | -5 600 | |
| | | 09 | | ការលក់សំភារៈបរិក្ខា | | | | |
| | | 10 | | ការជួលសំភារៈបរិក្ខា | | 2.0 | | +2 |
| | | 11 | | ផលនៃការជីកជញ្ជូនទំនិញ | | 80.8 | | +81 |
| | | 12 | | ផលនៃប្រតិបត្តិការពាណិជ្ជកម្ម | | 3.0 | | +3 |
| | | 13 | | ការផ្គត់ផ្គង់អគ្គិសនីនៅតាមខេត្តនានា (២) | | | | |
| | | 14 | | ផលខ្ទង់នៃរោងចក្រទឹក (២) | | | | |
| | | 20 | | ផលខ្ទង់ផ្សេងៗទៀតរបស់សហគ្រាសសាធារណៈ | 280.0 | 390.0 | | +110 |
| | 04 | | | កំរៃយកមុខក្នុងសម្បទានទ្រព្យសម្បត្តិរដ្ឋ | 11 500.0 | 18 857.4 | | +7 357 |
| | | 01 | | សម្បទានពីប្រេងកាត | 400.0 | 400.0 | | |
| | | 02 | | សម្បទានពីរ៉ែ | 1 100.0 | 1 997.4 | | +697 |
| | | 10 | | សម្បទានផ្សេងៗទៀត | 10 000.0 | 16 460.0 | | +6 460 |
| | 05 | | | ចំណូលពីការកាត់កាប់តម្លៃសិទ្ធិសាធារណៈ (២) | | | | |
| | | 01 | | ចំណូលការជួលកន្លែងលក់ដូរក្នុងផ្សារ | | | | |
| | | 02 | | ចំណូលពីចំណតរថយន្ត | | | | |
| | | 03 | | ចំណូលពីកំពង់ចំលង | | | | |
| | | 04 | | ចំណូលពីកន្លែងលក់ដោយការដេញថ្លៃ | | | | |
| | 06 | | | ការជួលអចលនវត្ថុ | 22 515.0 | 22 970.0 | | +455 |
| | 07 | | | ផលពីការលក់ផ្លែឈើ | 100.0 | | -100 | |
| | 08 | | | ផលបានមកពីការលក់ទ្រព្យសម្បត្តិដែលកំរិតសក្តានុពលធ្វើការ ការវាលការសការណ្ឋានម្ចាស់ និង ទំនិញបោះបង់ចោល | | | | |
| | 09 | | | ផលពីការលក់ចលនវត្ថុចាស់របស់រដ្ឋ | | | | |
| | 20 | | | ផលផ្សេងៗទៀតពីទ្រព្យសម្បត្តិរដ្ឋ | | 206.8 | | +2[illegible] |
| 21 | | | | ជំពូក២១: ចំណូលផ្សេងៗទៀតពុំមែនសារពើពន្ធ | 197 025.0 | 248 210.0 | | +51 1[illegible] |
| | 01 | | | ផលខ្ទង់ប្រៃសណីយ៍ និង ទូរគមនាគមន៍ | 161 000.0 | 150 280.0 | -10 720 | |
| | 02 | | | ផលខ្ទង់វិទ្យុ ទូរទស្សន៍ ការផ្សាយ | 420.0 | 285.0 | -135 | |

# ការគ្រប់គ្រងឆ្នាំ ២០០០

## តារាង "ក"

## ចំណូលថវិកាចរន្តរបស់រដ្ឋ

ការប្រមាណចំណូលតាមប្រភេទ ជំពូក ប្រការ កថាខណ្ឌ និង អនុកថាខណ្ឌ

ឯកតា: លានរៀល

| ជំពូក | ប្រការ | កថាខណ្ឌ | អនុកថាខណ្ឌ | ការរាយមុខចំណូល | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ១៩៩៩ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០០០ | លំអៀង ខ្វះ | លំអៀង លើស |
|---|---|---|---|---|---|---|---|---|
| | 03 | | | ចំណូលនៃសេវាកម្មសាធារណៈ | 32 875.0 | 80 592.2 | | -47 717 |
| | | 01 | | កំរៃនៃការថែទាំ | 18.0 | 42.0 | | -24 |
| | | 02 | | ការលក់សំភារៈសិក្សា | | | | |
| | | 03 | | អាករនៃស្ថានទូត | 19 450.0 | 23 570.0 | | -4 120 |
| | | 04 | | ផលទុននៃសកម្មភាពវប្បធម៌ | 290.0 | 320.0 | | -30 |
| | | 05 | | កម្រៃលើអាជ្ញាប័ណ្ណនាំឈើចេញ | 2 700.0 | 1 200.0 | -1 500 | |
| | | 06 | | ការត្រួតពិនិត្យគុណភាពផលិតផល | 4 202.0 | 4 828.3 | | -626 |
| | | 07 | | អាករលើការចុះបញ្ជីពាណិជ្ជកម្ម | 300.0 | 800.0 | | -500 |
| | | 08 | | ការបង់ប្រាក់ធានាសំរាប់បង្កើតសហគ្រាស | | | | |
| | | 09 | | ការលក់ឯកសារគយ | 20.0 | | -20 | |
| | | 10 | | លតាប័ត្រ និង លិខិតដោះពន្ធផ្សេងៗរបស់គយ | 1 500.0 | 2 000.0 | | -500 |
| | | 11 | | ឯកសារផ្សេងៗទៀត | 3 255.0 | 355.0 | -2 900 | |
| | | 12 | | ការលក់ឯកសារ និង លិខិតដោះពន្ធរបស់ពន្ធដារ | 100.0 | 108.5 | | -9 |
| | | 13 | | ផលនៃការលក់ផ្លាកលេខ | 500.0 | 633.4 | | -133 |
| | | 14 | | កម្រៃលើការធ្វើអត្តសញ្ញាណប័ណ្ណជាតិ | | | | |
| | | 15 | | អាករចុះបញ្ជីគណៈបក្សនយោបាយ | | | | |
| | | 16 | | ចំណូលពីឆ្នោត | | 50.0 | | -50 |
| | | 17 | | ចំណូលពីកូតានាំចេញ | | 46 000.0 | | -46 000 |
| | | | 01 | ចេញថ្លៃកូតា | | 10 000.0 | | -10 000 |
| | | | 02 | អាជ្ញាប័ណ្ណនាំចេញសំលៀកបំពាក់ | | 36 000.0 | | -36 000 |
| | | 30 | | ចំណូលផ្សេងៗទៀតរបស់សេវាកម្មសាធារណៈ | 540.0 | 685.0 | | -145 |
| | 04 | | | លំអៀងនៃអត្រាប្តូរប្រាក់ | | 40.0 | | -40 |
| | 05 | | | ចំណូលក្រៅសារពើពន្ធរបស់ខេត្តនានា | | | | |
| | 06 | | | ប្រាក់ចំណេញធនាគារជាតិ | | 15 000.0 | | -15 000 |
| | 20 | | | ចំណូលផ្សេងៗក្រៅពីសារពើពន្ធ | 2 730.0 | 2 012.8 | -717 | |
| | | | | **សរុបចំណូលជាមូលធន** | **275 000.0** | **870 000.0** | | **+595 000** |
| | | | | **ប្រភេទទី៣: ចំណូលជាមូលធន** | **275 000.0** | **870 000.0** | | **+595 000** |
| 30 | | | | ជំពូក៣០: ចំណូលផ្ទៃក្នុងជាមូលធន | 25 000.0 | 20 000.0 | -5 000 | |
| | 01 | | | ការលក់ទ្រព្យសម្បត្តិនៃមូលធនថេរ | | | | |
| | 02 | | | ការលក់ដីធ្លី | | | | |
| | 03 | | | ការលក់ទ្រព្យសកម្មអរូបិយ និង ហិរញ្ញវត្ថុ | | | | |
| | 04 | | | ផលឯកជនភាវូបនីយកម្ម | 25 000.0 | 20 000.0 | -5 000 | |
| | 15 | | | ចំណូលពីការវិបុលក្នុងប្រទេស | | | | |

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
ទំព័រ ៥ ៦

# ការគ្រប់គ្រងឆ្នាំ ២០០០

## តារាង "ក"

## ចំណូលថវិកាចរន្តរបស់រដ្ឋ

ការប្រមាណចំណូលតាមប្រភេទ ជំពូក ប្រការ កថាខណ្ឌ និង អនុកថាខណ្ឌ

ឯកតា: លានរៀល

| ជំពូក | ប្រការ | កថាខណ្ឌ | អនុកថាខណ្ឌ | ការរាយមុខចំណូល | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ១៩៩៩ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០០០ | លំអៀង ខ្វះ | លំអៀង លើស |
|---|---|---|---|---|---|---|---|---|
| 31 | | | | ជំពូក៣១: អំណោយពីបរទេស | 50 000.0 | 400 000.0 | | +350 000 |
| | 01 | | | ជំនួយមនុស្សធម៌ | | | | |
| | | 01 | | ..................................... | | | | |
| | 02 | | | មូលនិធិបដិភាគ | 50 000.0 | | -50 000 | |
| | | 01 | | ជប៉ុន | | | | |
| | | 02 | | អាល្លឺម៉ង់ | | | | |
| | | 03 | | បែលហ្ស៊ិក | | | | |
| | | 04 | | ចក្រភពអង់គ្លេស | | | | |
| | | 05 | | បារាំង | | | | |
| | | 06 | | អង្គការសហប្រជាជាតិ | | | | |
| | | 07 | | អ៊ីតាលី | | | | |
| | | 08 | | ស៊ុយអែត | | | | |
| | | 30 | | ផ្សេងៗទៀត | | | | |
| | 03 | | | អំណោយផ្សេងៗទៀតពីបរទេស | | 400 000.0 | | +400 000 |
| | | 01 | | ជប៉ុន | | | | |
| | | 02 | | សហរដ្ឋអាមេរិក | | | | |
| | | 03 | | អង្គការសហប្រជាជាតិ | | | | |
| | | 04 | | បារាំង | | | | |
| | | 05 | | អូស្ត្រាលី | | | | |
| | | 30 | | ផ្សេងៗទៀត | | | | |
| | 04 | | | អំណោយដោយឡែកសំរាប់រំលស់បំណុល | | | | |
| 32 | | | | ជំពូក៣២: ប្រភពទ្រព្យសម្បត្តិបានមកពីការខ្ចីបុល | 200 000.0 | 450 000.0 | | +250 000 |
| | 01 | | | ប្រភពខ្ចីពីក្នុង | | | | |
| | | 01 | | ប្រភពខ្ចីក្នុងបានមកពីប្រព័ន្ធធនាគារ | | | | |
| | | | 01 | ..................................... | | | | |
| | | 02 | | ប្រភពខ្ចីក្នុងផ្សេងៗទៀត | | | | |
| | | | 01 | ..................................... | | | | |
| | 02 | | | ប្រភពខ្ចីពីបរទេស | 200 000.0 | 450 000.0 | | +250 000 |
| | | 01 | | ប្រភពខ្ចីពីបរទេសបានមកពីអង្គការអន្តរជាតិនានា | 200 000.0 | 450 000.0 | | +250 000 |
| | | | 01 | ធនាគារពិភពលោក | 90 000.0 | 250 000.0 | | +160 000 |
| | | | | មូលនិធិបដិភាគ | | 150 000.0 | | +150 000 |
| | | | | គំរោងខ្ចី | 90 000.0 | 100 000.0 | | +10 000 |

# ការគ្រប់គ្រងឆ្នាំ ២០០០

## តារាង "ក"

## ចំណូលថវិកាទូទៅរបស់រដ្ឋ

ការប្រមាណចំណូលតាមប្រភេទ ជំពូក ប្រការ កថាខណ្ឌ និង អនុកថាខណ្ឌ

ឯកតា: លានរៀល

| ជំពូក | ប្រការ | កថាខណ្ឌ | អនុកថាខណ្ឌ | ការរាយមុខចំណូល | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ១៩៩៩ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០០០ | លំអៀង ខ្វះ | លំអៀង លើស |
|---|---|---|---|---|---|---|---|---|
| | | | 02 | ធនាគារអាស៊ីសំរាប់អភិវឌ្ឍន៍ | 110 000.0 | 200 000.0 | | +90 000 |
| | | | | មូលនិធិបដិភាគ | | | | |
| | | | | គំរោងទី | 110 000.0 | 200 000.0 | | +90 000 |
| | | | 03 | ................................... | | | | |
| | | 02 | | ប្រភពទុនខ្ចីពីបរទេសបានមកពីរដ្ឋាភិបាល និង អង្គការទំនាក់ទំនង | | | | |
| | | | 01 | ................................... | | | | |
| | | 03 | | ប្រភពទុនខ្ចីពីបរទេសបានមកពីអង្គការឯកជនទោនា | | | | |
| | | | 01 | ................................... | | | | |

(២) ចំណូលសារពើពន្ធ និង ក្រៅពីសារពើពន្ធ ដែលបានផ្ទេរអោយថវិកាខេត្ត ក្រុង ដោយអនុលោមទៅតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និង ទ្រព្យសម្បត្តិ របស់ខេត្ត ក្រុង ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ។

# ការគ្រប់គ្រងឆ្នាំ ២០០០

## តារាង "ខ"

## ចំណាយចរន្តរបស់រដ្ឋ



ការបែងចែកចំណាយតាមក្រសួង និង តាមប្រភេទ

ឯកតា: លានរៀល

| ប្រភេទ / ក្រសួងស្ថាប័ន | សរុបរួម នៃចំណាយ | សរុប ចំណាយជាប្រចាំ | ប្រភេទទី១ [illegible] | ប្រភេទទី២ ការប្រាក់ នៃការខ្ចីបុល | ប្រភេទទី៣ អន្តរាគមន៍ សាធារណៈ | ប្រភេទទី៤ ចំណាយផ្សេងៗនិង ចំ/យមិនបានគ្រោងទុក | ប្រភេទទី៥ សរុបចំណាយ ជាមូលធន |
|---|---|---|---|---|---|---|---|
| **សរុបរួមចំណាយ** | **2 355 000.0** | **1 315 000.0** | **1 031 950.0** | **25 000.0** | **177 050.0** | **81 000.0** | **1 040 000.0** |
| ***សរុបរដ្ឋបាលកណ្តាល*** | ***2 059 120.0*** | ***1 019 120.0*** | ***819 830.0*** | ***25 000.0*** | ***93 290.0*** | ***81 000.0*** | ***1 040 000.0*** |
| ***សរុបខេត្ត-ក្រុង*** | ***295 880.0*** | ***295 880.0*** | ***212 120.0*** | | ***83 760.0*** | | |
| ០១. ព្រះបរមរាជវាំង | 18 500.0 | 18 500.0 | 9 300.0 | | 9 200.0 | | |
| ០២. រដ្ឋសភា | 18 000.0 | 18 000.0 | 16 175.0 | | 1 825.0 | | |
| ០៣. ព្រឹទ្ធសភា | 9 000.0 | 9 000.0 | 8 555.0 | | 445.0 | | |
| ០៤. ក្រុមប្រឹក្សាធម្មនុញ្ញ | 1 950.0 | 1 950.0 | 1 915.0 | | 35.0 | | |
| ០៥. គណៈរដ្ឋមន្ត្រី | 40 365.0 | 40 365.0 | 35 730.0 | | 4 635.0 | | |
| *១. ទីស្តីការគណៈរដ្ឋមន្ត្រី* | 33 550.0 | 33 550.0 | 29 140.0 | | 4 410.0 | | |
| *២. រដ្ឋ.ផ្នែកមុខងារសាធារណៈ* | 595.0 | 595.0 | 590.0 | | 5.0 | | |
| *៣. រដ្ឋ.ផ្នែកអាកាសចរស៊ីវិល* | 4 000.0 | 4 000.0 | 3 800.0 | | 200.0 | | |
| *៤. ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា* | 2 220.0 | 2 220.0 | 2 200.0 | | 20.0 | | |
| ០៦. ក្រសួងការពារជាតិ | 311 200.0 | 311 200.0 | 296 600.0 | | 14 600.0 | | |
| ០៧. ក្រសួងមហាផ្ទៃ | 152 700.0 | 152 700.0 | 149 650.0 | | 3 050.0 | | |
| *១. សន្តិសុខសាធារណៈ* | 143 800.0 | 143 800.0 | 141 650.0 | | 2 150.0 | | |
| *២. រដ្ឋបាលទូទៅ* | 8 900.0 | 8 900.0 | 8 000.0 | | 900.0 | | |
| *៤. មន្ទ.ក្រុងខេត្ត* | | | | | | | |
| ០៨. ក្រសួងទំនាក់ទំ.ជាមួយរដ្ឋសភា.ព្រឹទ្ធសភា និងអធិការកិច្ច | 1 010.0 | 1 010.0 | 990.0 | | 20.0 | | |
| ០៩. ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ | 49 860.0 | 49 860.0 | 37 660.0 | | 12 200.0 | | |
| ១០. ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | 31 120.0 | 31 120.0 | 30 519.0 | | 601.0 | | |
| *១. ក្រសួង* | 29 120.0 | 29 120.0 | 28 620.0 | | 500.0 | | |
| *៤. មន្ទ.ក្រុងខេត្ត* | 2 000.0 | 2 000.0 | 1 899.0 | | 101.0 | | |
| ១១. ក្រសួងព័ត៌មាន | 5 500.0 | 5 500.0 | 5 410.0 | | 90.0 | | |
| *១. ក្រសួង* | 3 500.0 | 3 500.0 | 3 465.0 | | 35.0 | | |
| *៤. មន្ទ.ក្រុងខេត្ត* | 2 000.0 | 2 000.0 | 1 945.0 | | 55.0 | | |
| ១២. ក្រសួងសុខាភិបាល | 121 000.0 | 121 000.0 | 119 326.0 | | 1 674.0 | | |
| *១. ក្រសួង* | 81 000.0 | 81 000.0 | 80 100.0 | | 900.0 | | |
| *៤. មន្ទ.ក្រុងខេត្ត* | 40 000.0 | 40 000.0 | 39 226.0 | | 774.0 | | |

# ការគ្រប់គ្រងឆ្នាំ ២០០០

## តារាង "ខ"

## ចំណាយថវិកានុវត្តរបស់រដ្ឋ

ការបូកសរុបចំណាយតាមក្រសួង និង តាមប្រភេទ

ឯកតា: លានរៀល

| ប្រភេទ / ក្រសួងនានា | សរុបរួម នៃចំណាយ | សរុប ចំណាយជាប្រចាំ | ប្រភេទទី១ មធ្យោបាយសេវា | ប្រភេទទី២ ការប្រាក់ នៃការខ្ចីបុល | ប្រភេទទី៣ អន្តរាគមន៍ សាធារណៈ | ប្រភេទទី៤ ចំណាយផ្សេងៗនិង ទំ/ឬមិនបានគ្រោងទុក | ប្រភេទទី៥ សរុបចំណាយ ជាមូលធន |
|---|---|---|---|---|---|---|---|
| ១៣. ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល | 6 060.0 | 6 060.0 | 4 743.0 | | 1 317.0 | | |
| ១. ក្រសួង | 3 160.0 | 3 160.0 | 2 580 0 | | 580 0 | | |
| ៤. ខេត្ត-ក្រុងនានា | 2 900.0 | 2 900 0 | 2 163 0 | | 737 0 | | |
| ១៤. ក្រសួងផែនការ | 3 460.0 | 3 460.0 | 3 368.0 | | 92.0 | | |
| ១. ក្រសួង | 1 700.0 | 1 700.0 | 1 660 0 | | 40 0 | | |
| ៤. ខេត្ត-ក្រុងនានា | 1 760 0 | 1 760 0 | 1 708 0 | | 52.0 | | |
| ១៥. ក្រសួងពាណិជ្ជកម្ម | 7 070.0 | 7 070.0 | 5 944.0 | | 1 126.0 | | |
| ១. ក្រសួង | 5 170.0 | 5 170.0 | 4 150.0 | | 1 020.0 | | |
| ៤. ខេត្ត-ក្រុងនានា | 1 900.0 | 1 900.0 | 1 794.0 | | 106 0 | | |
| ១៦. ក្រសួងអប់រំ យុវជន និង កីឡា | 183 170.0 | 183 170.0 | 176 560.0 | | 6 610.0 | | |
| ១. អប់រំ | 35 320.0 | 35 320.0 | 34 800.0 | | 520 0 | | |
| ២. ឧត្តមសិក្សា | 11 280.0 | 11 280.0 | 10 270.0 | | 1 010.0 | | |
| ៣. យុវជន និង កីឡា | 7 280.0 | 7 280.0 | 6 300 0 | | 980.0 | | |
| ៤. ខេត្ត-ក្រុងនានា | 129 290.0 | 129 290.0 | 125 190.0 | | 4 100.0 | | |
| ១៧. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | 26 010.0 | 26 010.0 | 21 371.0 | | 4 639.0 | | |
| ១. ក្រសួង | 14 600.0 | 14 600.0 | 12 650 0 | | 1 950 0 | | |
| ៤. ខេត្ត-ក្រុងនានា | 11 410.0 | 11 410.0 | 8 721.0 | | 2 689 0 | | |
| ១៨. ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ | 7 500.0 | 7 500.0 | 7 084.0 | | 416.0 | | |
| ១. ក្រសួង | 4 700.0 | 4 700.0 | 4 420.0 | | 280.0 | | |
| ៤. ខេត្ត-ក្រុងនានា | 2 800.0 | 2 800 0 | 2 664.0 | | 136.0 | | |
| ១៩. ក្រសួងបរិស្ថាន | 4 000.0 | 4 000.0 | 3 868.0 | | 132.0 | | |
| ១. ក្រសួង | 2 600.0 | 2 600 0 | 2 510.0 | | 90 0 | | |
| ៤. ខេត្ត-ក្រុងនានា | 1 400.0 | 1 400 0 | 1 358.0 | | 42 0 | | |
| ២០. ក្រសួងអភិវឌ្ឍន៍ជនបទ | 8 100.0 | 8 100.0 | 7 918.0 | | 182.0 | | |
| ១. ក្រសួង | 3 700.0 | 3 700 0 | 3 680 0 | | 20 0 | | |
| ៤. ខេត្ត-ក្រុងនានា | 4 400.0 | 4 400 0 | 4 238 0 | | 162.0 | | |
| ២១. ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា | 26 900.0 | 26 900.0 | 4 922.0 | | 21 978.0 | | |
| ១. ក្រសួង | 2 900.0 | 2 900 0 | 2 335 0 | | 565 0 | | |
